ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពីលទ្ធផលនៃកិច្ចពិភាក្សាទូទៅក្នុងសម័យប្រជុំលើកទី៧២ នៃមហាសន្និបាតអង្គការសហប្រជាជាតិ (អ.ស.ប) និងកិច្ចប្រជុំផ្សេងទៀត
# ថ្ងៃទី១៩-២៥ ខែកញ្ញា ឆ្នាំ២០១៧
# ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក

--------

**ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូចូលរួមកិច្ចពិភាក្សាទូទៅក្នុងសម័យប្រជុំលើកទី៧២ នៃមហាសន្និបាតអ.ស.ប ក្រោមប្រធានបទ "ផ្ដោតលើប្រជាជនៈ ពុះពារដើម្បីសន្តិភាព និងជីវភាពសមរម្យសម្រាប់ទាំងអស់គ្នាលើភពផែនដីប្រកបដោយចីរភាព" និងកិច្ចប្រជុំផ្សេងៗទៀត ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ នាទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

## <u>កិច្ចពិភាក្សាទូទៅក្នុងសម័យប្រជុំលើកទី៧២ នៃមហាសន្និបាតអ.ស.ប</u>

ថ្លែងនាថ្ងៃទី ២២ ខែ កញ្ញា **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងអំពីទស្សនៈរបស់កម្ពុជាទាក់ទងនឹងការវិវត្តរបស់សណ្ដាប់ធ្នាប់សកលក្នុងពិភពលោកពហុប៉ូល ភាពងាយរងគ្រោះរបស់កម្ពុជាចំពោះបម្រែបម្រួលអាកាសធាតុ កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាឆ្ពោះទៅរកគោលដៅការអភិវឌ្ឍប្រកបដោយចីរភាព វិភាគទានរបស់កម្ពុជាចំពោះបេសកកម្មរក្សាសន្តិភាពដែលបានបញ្ជូនកងរក្សាសន្តិភាព ចំណាត់ការស្រេបច្បាប់របស់រាជរដ្ឋាភិបាលចំពោះបុគ្គល និងស្ថាប័នដែលរំលោភមកលើច្បាប់កម្ពុជា និងភាពលំអៀងនៃការចោទប្រកាន់នានាមកលើរាល់សកម្មភាពរបស់រាជរដ្ឋាភិបាលថា ជាការរំលោភសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ អាស្រ័យតាមផលប្រយោជន៍របស់មហាអំណាច ។

## <u>កិច្ចពិគ្រោះយោបល់ក្រៅផ្លូវការកម្រិតរដ្ឋមន្ត្រីការបរទេស នៃប្រទេសសមាជិកអង្គការហ្វ្រង់កូហ្វូនី</u> (ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧)

អង្គប្រជុំបានផ្ដោតយកបញ្ហា "សន្តិសុខ និងការអភិវឌ្ឍ" ដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការហ្វ្រង់កូហ្វូនី និងសេចក្ដីប្រកាស Saint Boniface ឆ្នាំ ២០០៦ ធ្វើជាចំណុចស្នូលនៃការពិចារណា និងសកម្ម

ភាពរួមគ្នា ជាពិសេសក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ហើយបានរំលឹកឡើងវិញនូវរូបមន្តរួមនៃការអភិវឌ្ឍដែលបានថ្លែងចេញក្នុងកិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិឆ្នាំ ២០០៥ ដែលថា "គ្មានទេការអភិវឌ្ឍប្រសិនបើគ្មានសន្តិសុខ ហើយគ្មានទេសន្តិសុខ បើគ្មានការអភិវឌ្ឍ" ។ អង្គប្រជុំក៏បានលើកអំពីមូលបទនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី ៣៣ ស្តីពី "សេដ្ឋកិច្ចថ្មី៖ សេដ្ឋកិច្ចខៀវ និងសេដ្ឋកិច្ចបៃតង ម៉ាស៊ីននៃកំណើនថ្មី បរិយាប័ន្នសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព" ដែលកិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៣-២៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅប្រទេសតូហ្គូ ។

**<u>កិច្ចប្រជុំកំពូល ស្តីពីកតិកាសញ្ញាសកលដើម្បីបរិស្ថាន</u>**
**(ថ្ងៃទី១៩ ខែកញ្ញា ២០១៧)**

ដឹកនាំដោយប្រទេសបារាំង កិច្ចប្រជុំនេះមានគោលបំណងសំខាន់ដើម្បីប្រកាសជាផ្លូវការនូវការចាប់ផ្តើមការពិគ្រោះយោបល់លើកតិកាសញ្ញាសកលដើម្បីបរិស្ថាន ដោយទទួលនូវធាតុចូលផ្សេងៗទាក់ទងនឹងការប្រឈម និងកាលានុវត្តភាពដែលអាចកើតចេញពីកតិកាសញ្ញាសកលនេះ ដើម្បីកំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋ និងសហគ្រាស ។

**<u>កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃក្រុមប្រទេសចលនាមិនចូលបក្សសម្ព័ន្ធ</u>**
**(ថ្ងៃទី២០ ខែកញ្ញា ២០១៧):**

មូលបទនៃកិច្ចប្រជុំគឺ "ការអនុម័ត និងអនុវត្តវិធានការបង្ខំជាឯកតោភាគីដែលផ្ទុយនឹងច្បាប់អន្តរជាតិ និងសិទ្ធិមនុស្សរបស់ប្រជាជនដែលរងគ្រោះ"។ អង្គប្រជុំបានអនុម័តលើឯកសារ២គឺ សេចក្តីថ្លែងការណ៍នៃគណៈកម្មាធិការរដ្ឋមន្ត្រីរបស់ចលនាមិនចូលបក្សសម្ព័ន្ធស្តីពីប៉ាឡេស្ទីន និងសេចក្តីថ្លែងការណ៍នយោបាយទីក្រុងញូវយ៉ក ដែលថ្លែងប្រឆាំងនឹងការអនុម័ត និងអនុវត្តវិធានការបង្ខំជាឯកតោភាគី ។ ក្នុងកិច្ចប្រជុំនេះ ប្រតិភូកម្ពុជាបានលើកឡើងពីបទពិសោធន៍របស់កម្ពុជាដែលធ្លាប់ទទួលរងទណ្ឌកម្មសេដ្ឋកិច្ចនានា និងវិធានការឯកតោភាគី ដែលពុំមែនជាដំណោះស្រាយដើម្បីសន្តិភាព និងវិបុលភាព ។

**<u>កិច្ចប្រជុំក្រៅផ្លូវការនៃសន្និសីទស្តីពីអន្តរសកម្មភាព និងវិធានការកសាងទំនុកចិត្តនៅអាស៊ី(CICA)</u>**
**(ថ្ងៃទី២០ ខែកញ្ញា ២០១៧):**

ទស្សនាទានសន្តិសុខអាស៊ីបន្តក្លាយជាបញ្ហាសំខាន់សម្រាប់ការពិចារណារបស់ CICA។ ការបន្តជំរុញការកសាងទំនុកចិត្តគឺជាកិច្ចការត្រូវតែបន្តធ្វើឲ្យបានច្រើន។ អង្គប្រជុំទាំងមូលបាននឹងកំពុងពិចារណាលើវិស័យសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍទាក់ទិននឹងរបៀបវារៈឆ្នាំ២០៣០ របស់អ.ស.ប។ គំនិតផ្តួចផ្តើមស្តីពីខ្សែក្រវ៉ាត់មួយ និងវិថីមួយត្រូវបានចាត់ទុកថានឹងជួយពន្លឿនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ។ អង្គប្រជុំក៏បានលើកបញ្ហាប្រែក្លាយ CICA ទៅជាអង្គការអន្តរជាតិ និងបានព្រមព្រៀងបោះពុម្ពសៀវភៅស្តីពីគម្រប់ខួប២៥ឆ្នាំ នៃការបង្កើត CICA និងការរៀបចំកិច្ចប្រជុំកំពូលនៅប្រទេសចិនឆ្នាំ២០១៨។

**កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃកិច្ចសន្ទនាស្តីពីសហប្រតិបត្តិការអាស៊ី**
**(ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧):**

អង្គប្រជុំបានផ្តោតការពិភាក្សាទៅលើគម្រោងសកម្មភាពនានាដែលបានអនុវត្តកន្លងមក ក្នុងក្របខ័ណ្ឌសសរស្តម្ភអាទិភាពទាំង៦របស់កិច្ចសន្ទនាសហប្រតិបត្តិការអាស៊ី (ACD) គឺ៖ ១) ការតភ្ជាប់ ២) វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្ត ៣) អប់រំ និងការអភិវឌ្ឍធនធានមនុស្ស ៤) អន្តរទំនាក់ទំនងរវាងសន្តិសុខស្បៀង ថាមពល និងទឹក ៥) វប្បធម៌ និងទេសចរណ៍ និង ៦)ការលើកកម្ពស់អភិក្រមសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។ កម្ពុជាដែលជាសហប្រទេសនាំមុខ(Co-prime mover) សម្រាប់សសរស្តម្ភទី៥ (វប្បធម៌ និងទេសចរណ៍) បានរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃកិច្ចប្រជុំកម្រិតខ្ពស់នៃមន្ត្រីទទួលបន្ទុកវិស័យទេសចរណ៍និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ ACD លើកទី២ ក្នុងឱកាសសន្និសីទអន្តរជាតិ UNESCO/UNWTO លើកទី១ ស្តីពីវិស័យទេសចរណ៍ប្រកបដោយចីរភាព និងទីក្រុងបេតិកភ័ណ្ឌ នាថ្ងៃទី១១-១៦ ខែមិថុនា ឆ្នាំ២០១៧ នៅទីក្រុងសៀមរាប។

**កិច្ចប្រជុំប្រចាំឆ្នាំ ថ្នាក់រដ្ឋមន្ត្រីនៃក្រុមប្រទេស G-77 + China លើកទី៤១**
**(២២ ខែកញ្ញា ឆ្នាំ២០១៧):**

ក្នុងកិច្ចប្រជុំនេះ រដ្ឋមន្ត្រីការបរទេសនៃក្រុមប្រទេស៧៧ និងចិនបានធ្វើការពិភាក្សាយ៉ាងទូលំទូលាយទៅលើប្រធានបទសំខាន់ៗចំនួនពីរ ដែលជាស្នូលនៃកិច្ចសហប្រតិបត្តិការរបស់ក្រុមប្រទេស៧៧ និងចិន គឺ៖ (១) ការធ្វើហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ និងពង្រឹងក្របខ័ណ្ឌសហប្រតិបត្តិការអន្តរជាតិ ទៅលើវិស័យសារពើពន្ធ និង(២) តួនាទីរបស់ក្រុមប្រទេស៧៧ ក្នុងការលើកកម្ពស់ការអនុវត្តរបៀបវារៈអភិវឌ្ឍន៍ឆ្នាំ២០៣០ ក្នុងស្មារតីនៃការរំឭកខួបទី៥០នៃធម្មនុញ្ញអាល់ហ្សេរ (Charter of Algiers) ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រុមប្រទេស៧៧លើកទី១ ក្នុងឆ្នាំ១៩៦៧។

**កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDCs)**
**(ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៧):**

ប្រទេសអភិវឌ្ឍន៍តិចតួចទាំងអស់ បានស្វាគមន៍ចំពោះការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតធនាគារបច្ចេកវិទ្យា និងកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន និងការគាំទ្រដល់ធនាគារខាងលើនេះ ។ កិច្ចប្រជុំនេះបានអនុម័តលើសេចក្តីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រីនៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីជាឯកសារបង្ហាញផ្លូវសំរាប់ពន្លឿនការអភិវឌ្ឍនៅប្រទេសអភិវឌ្ឍន៍តិចតួច និងជំរុញការអនុវត្តផែនការសកម្មភាពក្រុងអ៊ីស្តង់ប៊ូល។ កម្ពុជាបានជម្រាបជូនអង្គប្រជុំអំពីការអភិវឌ្ឍរបស់កម្ពុជា និងការប្រែក្លាយពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៦ ។ កម្ពុជាបានស្វាគមន៍ការផ្តើមដំណើរការធនាគារបច្ចេកវិទ្យា (Technology Bank) នៅតួកគីក្នុងពេលឆាប់ៗនេះ ។

ស្ស

## ជំនួបទ្វេភាគី (២១-២២ ខែកញ្ញា ឆ្នាំ២០១៧)

**ឯកឧត្តមទេសរដ្ឋមន្ត្រី**បានជួបជាលក្ខណៈទ្វេភាគីប្រកបដោយផ្លែផ្កាជាច្រើន ជាមួយលោកជំទាវ ម៉ារីយ៉ា អេនជេឡា ហូលហ្គេន គូអេឡា (Maria Angela Holguin Cuellar) រដ្ឋមន្ត្រីការបរទេសកូឡុំប៊ី ឯកឧត្តម ប្រ៊ូណូ អេដាដូ រ៉ូឌ្រីហ្គេ ផារីឡា (Brono Eduardo R. Parrila) រដ្ឋមន្ត្រីការបរទេសគុយបា ឯកឧត្តម ម៉ាក ហ្វៀល (Mark Field) អនុរដ្ឋមន្ត្រីការបរទេសចក្រភពអង់គ្លេសទទួលបន្ទុកអាស៊ី-ប៉ាស៊ីហ្វិក ឯកឧត្តម បណ្ឌិត អាន់វ៉ា ម៉ូហាំម៉ាត់ ហ្គាហ្គាស់ (Anwar Mohammad Gargash) រដ្ឋមន្ត្រីការបរទេសនៃអាណាចក្រសម្ព័ន្ធអារ៉ាប់ និងលោកជំទាវ ស៊ូសាន ថនតុន (Susan A. Thornton) ឧបការីរងស្ដីទីទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៃក្រសួងការបរទេសសហរដ្ឋអាមេរិក។

ក្នុងអំឡុងកិច្ចប្រជុំទ្វេភាគីជាមួយលោកជំទាវ គូអេឡា រដ្ឋមន្ត្រីការបរទេសកូឡុំប៊ី **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូឡុំប៊ី ស្ដីពីការលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ។

## កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការ និងកិច្ចប្រជុំពាក់ព័ន្ធ (ថ្ងៃទី២២-២៣ ខែកញ្ញា ឆ្នាំ២០១៧)

កិច្ចប្រជុំទាំងនេះធ្វើឡើងជាប្រចាំរវាងរដ្ឋមន្ត្រីការបរទេសអាស៊ាននិងសមភាគី នៅស្របពេលនឹងមហាសន្និបាតអង្គការសហប្រជាជាតិ (អ.ស.ប) ។

ក្រៅពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការ រដ្ឋមន្ត្រីការបរទេសអាស៊ានបានជួបប្រជុំជាមួយឯកឧត្តម Antonio Guterres អគ្គលេខាធិការនៃអ.ស.ប និងឯកឧត្តម Miroslav Lajčák ប្រធានសម័យប្រជុំលើកទី ៧២ របស់មហាសន្និបាតអ.ស.ប (កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននិងអ.ស.ប)។ រដ្ឋមន្ត្រីការបរទេសអាស៊ានក៏បានជួបប្រជុំផ្សេងទៀតជាមួយនឹងសមភាគីមកពីសម្ព័ន្ធភាពប៉ាស៊ីហ្វិក (Pacific Alliance) និងកិច្ចសហប្រតិបត្តិការទីផ្សាររួមអាមេរិកខាងត្បូង (MERCOSUR) ដើម្បីជំរុញទំនាក់ទំនងខាងក្រៅរបស់អាស៊ានជាមួយនឹងក្រុមប្រទេសតាមតំបន់ទាំងនេះ។

កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការ បានកត់សម្គាល់លើបញ្ជីបេក្ខភាពអាស៊ានសម្រាប់អង្គភាពនានារបស់អ.ស.ប និងក្នុងស្ថាប័នអន្តរជាតិផ្សេងៗ ដែលក្នុងនោះមានបេក្ខភាពរបស់កម្ពុជាសម្រាប់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អ.ស.ប (ECOSOC) សម្រាប់អាណត្តិឆ្នាំ២០១៩ និងជាអនុប្រធាននៃសម័យប្រជុំលើកទី៧៣ របស់មហាសន្និបាតអ.ស.ប សម្រាប់ខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩។ រដ្ឋមន្ត្រីការបរទេសអាស៊ានក៏បានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការគាំទ្រគ្នាទៅវិញទៅមកលើបេក្ខភាពរបស់អាស៊ាន ដើម្បីរក្សាបាននូវទំនាក់ទំនង និងភាពបុរេសកម្មរបស់អាស៊ាន នៅក្នុងអង្គភាពនានារបស់អ.ស.ប។ រដ្ឋមន្ត្រីការបរទេសអាស៊ានបានស្ដាប់អំពីសេចក្ដីរាយការណ៍នៃការវិវឌ្ឍថ្មីៗនៅភាគខាងជើងនៃរដ្ឋរ៉ាខាញរបស់មីយ៉ាន់ម៉ា ហើយប្រធានអាស៊ានបានចេញនូវសេចក្ដីប្រកាសរបស់ខ្លួនស្ដីពី

ស្ថានភាពមនុស្សធម៌ នៅរដ្ឋរ៉ាខាញ។ ហ្វីលីពីនក៏បានជម្រាបជូនអំពីការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលនឹងប្រព្រឹត្តទៅឡើងនៅខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមុខនេះផងដែរ។

សម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននិងអ.ស.ប កិច្ចប្រជុំបានពិភាក្សាស្តីពីការលើកកម្ពស់បន្ថែមទៀតនូវសហប្រតិបត្តិការអាស៊ាន-អ.ស.ប និងបានពិនិត្យឡើងវិញនូវការអនុវត្តផែនការសកម្មភាពដើម្បីអនុវត្តសេចក្តីថ្លែងការណ៍រួមគ្នាស្តីពីភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងអាស៊ាននិងអ.ស.ប (២០១៦-២០២០)។ កិច្ចប្រជុំបានកត់សម្គាល់នូវរបាយការណ៍រួមស្តីពីភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងអ.ស.ប សម្រាប់រយៈពេលចាប់ពីខែកញ្ញា ឆ្នាំ២០១៦ ដល់ខែសីហា ឆ្នាំ២០១៧ និងបានយល់ព្រមឲ្យមានការរៀបចំកិច្ចប្រជុំរវាងលេខាធិការដ្ឋានអាស៊ាន និងលេខាធិការដ្ឋានអ.ស.ប ចំនួនពីរដងក្នុងមួយឆ្នាំ គឺ ១ដងនៅទីក្រុងហ្សាការតា និង១ដងទៀតនៅទីក្រុងញ៉ូវយ៉ក នៅស្របពេលជាមួយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននិងអ.ស.ប។ កិច្ចប្រជុំក៏បានផ្លាស់ប្តូរទស្សនៈប្រកបដោយផ្លែផ្កាលើបញ្ហាតំបន់និងអន្តរជាតិដែលជាការព្រួយបារម្ភរួម រួមមានការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ការទប់ស្កាត់អំពើហិង្សាជ្រុលនិយម សន្តិសុខតំបន់ ទេសន្តរប្រវេសន៍ និងរបៀបវារៈ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព រួមបញ្ចូលទាំងការជំរុញនូវភាពបំពេញបន្ថែមគ្នារវាងផែនការលម្អិតស្តីពីសហគមន៍អាស៊ានឆ្នាំ ២០២៥ និងរបៀបវារៈឆ្នាំ២០៣០ របស់អ.ស.បសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ហ្វីលីពីនក៏បានជម្រាបជូនអំពីការត្រៀមរៀបចំកិច្ចប្រជុំអាស៊ាន-អ.ស.ប លើកទី៩ ដែលនឹងប្រព្រឹត្តទៅឡើងនៅខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងម៉ានីល។

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សម្ព័ន្ធភាពប៉ាស៊ីហ្វិកលើកទី៤ ត្រូវបានរៀបចំ និងក្រោមសហប្រធានឯកឧត្តម Pham Binh Minh ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយនឹងលោកជំទាវ Maria Angela Holguin Cuellar រដ្ឋមន្ត្រីការបរទេសកូឡុំប៊ី ដើម្បីពង្រឹងទំនាក់ទំនងអាស៊ានជាមួយនឹងសម្ព័ន្ធភាពប៉ាស៊ីហ្វិក។ កិច្ចប្រជុំបានស្តាប់សេចក្តីរាយការណ៍អំពីការវិវឌ្ឍថ្មីៗនៅក្នុងអាស៊ាន និងសម្ព័ន្ធភាពប៉ាស៊ីហ្វិក។ រដ្ឋមន្ត្រីការបរទេសមានក្តីសោមនស្សរីករាយចំពោះការសម្រេចបាននូវ "ផែនការការងារអាស៊ាន-សម្ព័ន្ធភាពប៉ាស៊ីហ្វិក សម្រាប់ឆ្នាំ២០១៧-២០១៨ ស្តីពីការអនុវត្តអាណត្តិ និងទិសដៅពេលអនាគត" ហើយរំពឹងនូវការអនុវត្តដោយពេញលេញ និងទាន់ពេលវេលានូវផែនការការងារនេះ។ ផែនការការងារនេះឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តដ៏មុតមាំនៃប្រទេសសមាជិកអាស៊ាន និងសម្ព័ន្ធភាពប៉ាស៊ីហ្វិក ក្នុងការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ការអប់រំ និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព។

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចសហប្រតិបត្តិការទីផ្សាររួមអាមេរិកខាងត្បូង (MERCOSUR) លើកទី២ ត្រូវបានរៀបចំ និងក្រោមសហប្រធានលោកជំទាវ Retno LP Marsudi រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋឥណ្ឌូនេស៊ី ជាមួយនឹងឯកឧត្តម Aloysio Nunes Ferreira Filho រដ្ឋមន្ត្រីការបរទេសប្រេស៊ីល។ រដ្ឋមន្ត្រីការបរទេសបានសង្កត់ធ្ងន់លើសារសំខាន់នៃការរិះរកមធ្យោបាយ ដើម្បីពង្រឹងបន្ថែមទំនាក់ទំនងសេដ្ឋកិច្ចរវាង MERCOSUR និងប្រទេសសមាជិកអាស៊ាន រួមទាំងកិច្ចសហប្រតិបត្តិការ

លើការអភិវឌ្ឍប្រកបដោយចីរភាព ទេសចរណ៍ ការតភ្ជាប់ នវានុវត្ត និងការភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និងប្រជាជន និងរំពឹងការលើកកម្ពស់ក្នុងផ្លាស់ប្តូរព័ត៌មានឲ្យបានទៀងទាត់ សម្រាប់កាលានុវត្តភាពពាណិជ្ជកម្ម ការវិនិយោគ ជាពិសេសសហគ្រាសមីក្រូ-ធុនតូចនិងមធ្យមរវាងតំបន់ទាំងពីរ។ កិច្ចប្រជុំក៏បានចែករំលែកនូវទស្សនៈអំពីតម្រូវការ ដើម្បីពង្រឹងកិច្ចសហប្រត្តិបត្តិការ ASEAN-MERCOSUR និងបានសង្កត់ធ្ងន់លើសារសំខាន់ឲ្យមានការរៀបចំកិច្ចប្រជុំទៀងទាត់ រវាងឯកអគ្គរដ្ឋទូតនៃប្រទេស MERCOSUR និងគណៈកម្មាធិការអចិន្ត្រៃយ៍ប្រចាំអាស៊ាន នៅទីក្រុងហ្សាការតា ដើម្បីបញ្ចប់ការតាក់តែងផែនការសកម្មភាព ASEAN-MERCOSUR និងបានឯកភាពឲ្យចាប់ផ្តើមកិច្ចសហប្រតិបត្តិការរវាងលេខាធិការដ្ឋាន និងលេខាធិការដ្ឋាននៃតំបន់ទាំងពីរ។ កិច្ចប្រជុំបានចេញនូវសេចក្តីប្រកាសព័ត៌មានដែលជាឯកសារលទ្ធផលនៃកិច្ចប្រជុំ។

ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៧